00793937

E172/10

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 28 / 03 / 2012
ម៉ោង (Time/Heure) : 11:35
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: SANN RADA

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

# អង្គជំនុំជម្រះសាលាដំបូង

ថ្ងៃទី ២៨ ខែ មីនា ឆ្នាំ ២០១២

**ជូនចំពោះ:** ភាគីនៃសំណុំរឿង ០០២

**ពី:** ចៅក្រម និល ណុន ប្រធានអង្គជំនុំជម្រះសាលាដំបូង

**ចម្លងជូន:** លោក/លោកស្រីចៅក្រមទាំងអស់នៃអង្គជំនុំជម្រះសាលាដំបូង,មន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង

**កម្មវត្ថុ:** លំដាប់លំដោយនៃការស្តាប់សក្ខីកម្មសាក្សីដែលត្រូវបានកែប្រែ សម្រាប់ចំណុចអង្គហេតុដែលត្រូវធ្វើសវនាការនាពេលបច្ចុប្បន្នលើសំណុំរឿង ០០២/០១

បន្ថែមពីលើអនុស្សរណៈរបស់ខ្លួនចុះថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ ២០១២ (ឯកសារ E172) អង្គជំនុំជម្រះសូមជូនដំណឹងទៅភាគីថាសាក្សីទាំងឡាយដែលសក្ខីកម្មរបស់ពួកគាត់ រំពឹងថានឹងផ្តោតទៅលើប្រព័ន្ធទំនាក់ទំនងការងារនោះ នៅពេលនេះនឹងត្រូវអង្គជំនុំជម្រះស្តាប់សក្ខីកម្មនៅចុងបញ្ចប់នៃសវនាការលើចំណុចអង្គហេតុនាពេលបច្ចុប្បន្ន (រចនាសម្ព័ន្ធរដ្ឋបាល និងប្រព័ន្ធទំនាក់ទំនងទងការងារ និងធាតុផ្សំមួយចំនួននៃតួនាទីរបស់ជនជាប់ចោទ)។ បន្ទាប់ពីបញ្ចប់ការស្តាប់សក្ខីកម្មរបស់សាក្សី កាំង ហ្កេកអ៊ាវ *ហៅ ឌុច* អង្គជំនុំជម្រះនឹងស្តាប់សក្ខីកម្មរបស់សាក្សីខាងក្រោម ទៅតាមលំដាប់លំដោយដូចតទៅ៖

*រចនាសម្ព័ន្ធរដ្ឋបាល (មជ្ឈិម)*

សាក្សីដែលមានរហស្សនាម TCW-617

សាក្សីដែលមានរហស្សនាម TCW-504

សាក្សីដែលមានរហស្សនាម TCW-488

*ក្រសួងមន្ទីរ (មន្ទីរ ប-១, ក្រសួងការបរទេស)*

សាក្សីដែលមានរហស្សនាម TCW-586

សាក្សីដែលមានរហស្សនាម TCW-323

សាក្សីដែលមានរហស្សនាម TCW-487

*ក្រសួងមន្ទីរ (ក្រសួងពាណិជ្ជកម្ម)*

សាក្សីដែលមានរហស្សនាម TCW-583

សាក្សីដែលមានរហស្សនាម TCW-321

ការស្តាប់សក្ខីកម្មរបស់សាក្សីដែលនៅសេសសល់ដូចដែលមានរាយនាមនៅក្នុងឯកសារ E172 នឹងគ្រោងធ្វើនៅពេលក្រោយ នៅពេលដែលមានការបញ្ជាក់អំពីវត្តមានរបស់ពួកគាត់។ ដូច្នេះសូមភាគីជ្រាបថាសាក្សីនានាក្នុងចំណោមសាក្សីដូចមានរាយនាមនៅក្នុងឯកសារ E172 អាចត្រូវបានស្តាប់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះ ហើយលំដាប់លំដោយខាងលើអាចកែប្រែនៅពេលការរៀបចំសវនាការប្រកបដោយប្រសិទ្ធភាពតម្រូវដូច្នេះ។ ក្នុងករណីដែលជនជាប់ចោទសម្រេចចិត្តផ្តល់សក្ខីកម្ម សាក្សីក៏អាចត្រូវបានអង្គជំនុំជម្រះស្តាប់សក្ខីកម្មផងដែរក្នុងអំឡុងសវនាការរយៈពេលកន្លះថ្ងៃតាមការចាំបាច់។

ដូចអង្គជំនុំជម្រះធ្លាប់បានបញ្ជាក់នាពេលកន្លងមក អង្គជំនុំជម្រះនឹងផ្តល់ព័ត៌មានពាក់ព័ន្ធនឹងបុគ្គលមួយចំនួនដែលសហព្រះរាជអាជ្ញាបានស្នើសុំស្តាប់សក្ខីកម្មក្នុងនាមជាអ្នកជំនាញក្នុងពេលដ៏ខ្លីខាងមុខ។